# សេចក្តីជូនដំណឹង

## ស្តីពី

## ការផ្លាស់ប្តូរកិច្ចប្រជុំមហាសន្និបាតភាគហ៊ុនិក របស់ធនាគារ អេស៊ីលីដា ភីអិលស៊ី លើកទី២១

ធនាគារ អេស៊ីលីដា ភីអិលស៊ី (ធនាគារ) មានកិត្តិយស សូមជម្រាបជូនដំណឹងដល់ភាគហ៊ុនិកទាំងអស់របស់ធនាគារថា កាលពីថ្ងៃទី១ ខែមេសា ឆ្នាំ២០២១ ធនាគារបានផ្ញើសេចក្តីជូនដំណឹងដល់ភាគហ៊ុនិកទាំងអស់ ស្តីពីកិច្ចប្រជុំមហាសន្និបាតភាគហ៊ុនិករបស់ធនាគារ លើកទី២១ (កិច្ចប្រជុំ) ដែលនឹងរៀបចំនៅថ្ងៃទី២២ ខែមេសា ឆ្នាំ២០២១ នៅម៉ោង ១៤:០០ រសៀល នៅការិយាល័យកណ្តាលរបស់ធនាគារ។ ធនាគារសូមជម្រាបជូនដំណឹងដល់ភាគហ៊ុនិកទាំងអស់ អំពីការផ្លាស់ប្តូរកិច្ចប្រជុំនេះ ពី**ការប្រជុំផ្ទាល់នៅការិយាល័យកណ្តាលរបស់ធនាគារ** ទៅជា **ការប្រជុំតាមរយៈអ៊ីម៉ែល**។ ការផ្លាស់ប្តូរកិច្ចប្រជុំនេះ គឺដោយសារតែមូលហេតុចម្បងៗ មួយចំនួន ដូចខាងក្រោម៖

១. ការរីករាលដាលនៃជំងឺកូវីដ-១៩ នៅក្នុងសហគមន៍ និងស្ថានភាពមិនទាន់ធូរស្រាល នាពេលបច្ចុប្បន្ន និងការចូលរួមចំណែកជាមួយនឹងរាជរដ្ឋាភិបាលក្នុងការទប់ស្កាត់ការរីករាលដាល នៃជំងឺកាចសាហាវនេះ។
២. ការរៀបចំកិច្ចប្រជុំតាម Conference Call ពុំមានប្រសិទ្ធភាព ដោយសារធនាគារមានភាគហ៊ុនិកសាធារណៈចំនួនច្រើន។
៣. ដើម្បីធ្វើឲ្យកិច្ចប្រជុំនេះអាចដំណើរការទៅដោយរលូន តាមកាលបរិច្ឆេទកំណត់។

សូមភាគហ៊ុនិកទាំងអស់មេត្តាត្រួតពិនិត្យមើលឯកសារគាំទ្រ និងការណែនាំអំពីការបោះឆ្នោត ដែលធនាគារនឹងផ្ញើជូនតាមអ៊ីម៉ែល។

ដំណើរការនៃការបោះឆ្នោតមានដូចខាងក្រោម៖

- ធនាគារនឹងផ្ញើ QR Code សម្រាប់ការបោះឆ្នោត ជូនភាគហ៊ុនិកម្នាក់ៗ តាមរយៈអ៊ីម៉ែល ក្នុងអំឡុងថ្ងៃទី១៩ ខែមេសា ឆ្នាំ២០២១ ចាប់ពីម៉ោង ៧:៣០ ព្រឹក រហូតដល់ថ្ងៃទី២២ ខែមេសា ឆ្នាំ២០២១ វេលាម៉ោង ១៤:០០ រសៀល (ម៉ោងនៅភ្នំពេញ)។
- ភាគហ៊ុនិកម្នាក់ៗ ត្រូវបោះឆ្នោតនៅថ្ងៃទី២២ ខែមេសា ឆ្នាំ២០២១ ក្នុងចន្លោះពេលណាមួយ ចាប់ពីម៉ោង ១៤:០០ វេលាម៉ោង ១៦:០០ រសៀល (ម៉ោងនៅភ្នំពេញ) ដោយបើកកាមេរ៉ាទូរស័ព្ទដៃ ឬ Tablet របស់លោក/អ្នក រួចស្កេន QR Code ដែលបានភ្ជាប់ជូនមកជាមួយនឹងអ៊ីម៉ែល។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមភាគហ៊ុនិកទាំងអស់ មេត្តាជ្រាបជាព័ត៌មាន និងចូលរួមកិច្ចប្រជុំតាមរយៈអ៊ីម៉ែលនេះ តាមកាលបរិច្ឆេទកំណត់ ដោយសេចក្តីអនុគ្រោះ។ ប្រសិនបើលោក/អ្នកមានតម្រូវការ ឬសំណួរផ្សេងៗ សូមទំនាក់ទំនងមកភ្នាក់ងារចុះបញ្ជីផ្ទេរមូលបត្ររបស់ធនាគារ អេស៊ីលីដា ភីអិលស៊ី ដូចខាងក្រោម៖

- **លោក លីម អាន** ប្រធានផ្នែកប្រតិបត្តិការ RTP
  - ទូរស័ព្ទ: (៨៥៥) ១៥ ៦០០ ៧៤៣
  - អ៊ីម៉ែល: lim.an@acledabank.com.kh
- **លោក ហួត សុភី** អនុប្រធានផ្នែកប្រតិបត្តិការ RTP
  - ទូរស័ព្ទ: (៨៥៥) ១៥ ៩០០ ៥៣៨
  - អ៊ីម៉ែល: huot.sophy@acledabank.com.kh

- **លោកស្រី សំរិទ្ធ វណ្ណីបុប្ផារដ្ឋ** បុគ្គលិកផ្នែកប្រតិបត្តិការ RTP
    - ទូរស័ព្ទ: (៨៥៥) ៦១ ២៨៧ ៧៦៦
    - អ៊ីម៉ែល: op.rtp@acledabank.com.kh

ថ្ងៃចន្ទ ១កើត ខែពិសាខ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤
រាជធានីភ្នំពេញ ថ្ងៃទី១២ ខែមេសា ឆ្នាំ២០២១

**ធនាគារ អេស៊ីលីដា ភីអិលស៊ី**